**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៤១១ ព.ណ.ចបព

ថ្ងៃពុធ ១រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកវគ្គបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ជំនាន់ទី៣)

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនទាំងអស់មេត្តាជ្រាបថា ក្រសួងពាណិជ្ជកម្ម នឹងរៀបចំវគ្គបណ្តុះបណ្តាល អំពីច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធព្រមទាំងនីតិវិធីនានាជូនដល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ជំនាន់ទី៣) ក្នុងគោលបំណងគ្រប់គ្រង និងពង្រឹងសមត្ថភាពអ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន-សហគ្រាស បង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងគាំទ្រដល់ការផ្តល់សេវាចុះបញ្ជីពាណិជ្ជកម្មឱ្យកាន់តែប្រសើរឡើង ស្របតាមស្មារតីប្រកាសលេខ ២៥៨ ព.ណ ចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

អ្នកដែលមានបំណងចូលរួមក្នុងវគ្គបណ្តុះបណ្តាលខាងលើ ត្រូវដាក់ពាក្យស្នើសុំតាមរយៈសារអេឡិចត្រូនិក business.reg.info@gmail.com ចាប់ពីម៉ោង ៨:០០ នាទីព្រឹក ថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២២ នេះតទៅ។ ក្រសួងពាណិជ្ជកម្ម នឹងបញ្ចប់ការទទួលពាក្យស្នើសុំត្រឹម១០០ នាក់ដំបូង ដែលបានផ្ញើពាក្យស្នើសុំតាមរយៈសារអេឡិចត្រូនិក និងតាមពេលវេលាកំណត់ខាងលើ។ អ្នកស្នើសុំអាចទាញពាក្យស្នើសុំពីគេហទំព័រក្រសួងពាណិជ្ជកម្មhttps://www.businessregistration.moc.gov.kh/wp-content/uploads/2018/02/Application-Form-20-Feb-2018.pdf និងត្រូវបំពេញពាក្យស្នើសុំដោយភ្ជាប់មកជាមួយនូវឯកសារតម្រូវតាមប្រកាស ២៥៨ ព.ណ ចបព.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ជាទម្រង់ PDF រួចផ្ញើមកសារអេឡិចត្រូនិកដូចមានភ្ជាប់ជូនខាងលើ។ ពាក្យស្នើសុំនឹងត្រូវចាត់ទុកថាបានទទួល តាមរយៈសារអេឡិចត្រូនិកដែលបានផ្ញើមកតាមលំដាប់លំដោយ តាមលេខរៀង និងតាមពេលវេលាម៉ោងដែលបានស្នើសុំរហូតដល់គ្រប់ចំនួនកំណត់។

បេក្ខជនដែលបានផ្ញើសារអេឡិចត្រូនិក១០០ នាក់ដំបូង ត្រូវយកពាក្យស្នើសុំ និងឯកសារតម្រូវច្បាប់ដើមមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មក្រោយពីទទួលបានការជូនដំណឹងពីក្រសួងពាណិជ្ជកម្មតាមរយៈសារអេឡិចត្រូនិកត្រឡប់ជូនវិញ។

ក្រសួងពាណិជ្ជកម្ម នឹងប្រកាសបញ្ជីឈ្មោះបេក្ខជនដែលត្រូវចូលរួមវគ្គបណ្តុះបណ្តាលជំនាន់ទី៣ ដែលស្ថិតនៅក្នុងលំដាប់លេខរៀងសារអេឡិចត្រូនិកបានផ្ញើមក១០០ នាក់ដំបូងហើយបានបំពេញពាក្យស្នើសុំត្រឹមត្រូវ និងភ្ជាប់ឯកសារតម្រូវគ្រប់គ្រាន់។

ចំពោះបេក្ខជនដែលមិនបានបំពេញលក្ខខណ្ឌខាងលើ នឹងមិនត្រូវបានជ្រើសរើសក្នុងបញ្ជីឈ្មោះបេក្ខជនដែលត្រូវចូលរៀនវគ្គបណ្តុះបណ្តាលជំនាន់ទី៣នោះទេ ទោះបីស្ថិតក្នុងលំដាប់លេខរៀងពីទី១ដល់ទី១០០ក៏ដោយ ក្រសួងនឹងកំណត់យកបេក្ខជនដែលមានលំដាប់លេខរៀងបន្ទាប់ពីលេខ១០០ ឡើងទៅដែលបានបំពេញលក្ខខណ្ឌត្រឹមត្រូវមកជំនួសវិញ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ឬតាមរយៈលេខទូរស័ព្ទ ០៩៦ ៩៦៣ ២៣៦៣ / ០៨៨ ៦០៨ ៣០៨២ ដែលមាន Extension លេខ០ ឬ៣។

សូមអរគុណ!

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ក្រសួងពាណិជ្ជកម្ម

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

រូបថត
4x6

## ពាក្យស្នើសុំចូលរៀន
## វគ្គបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម

| ១. ព័ត៌មានផ្ទាល់ខ្លួន | | | |
|---|---|---|---|
| ឈ្មោះ(ខ្មែរ) | | ភេទ... | ស្ថានភាពគ្រួសារ...... |
| ឈ្មោះ(ឡាតាំង) | | ថ្ងៃខែឆ្នាំកំណើត......../........../........ | |
| ទីកន្លែងកំណើត | | | |
| អាសយដ្ឋានបច្ចុប្បន្ន | | | |
| អ៊ីម៉ែល E-mail | | លេខទូរស័ព្ទ............... | |
| មុខរបរ | | សញ្ជាតិ..................... | |

| ២. កម្រិតសិក្សា (ចាប់ពីមធ្យមសិក្សា រហូតដល់ឧត្តមសិក្សា) | | |
|---|---|---|
| មុខជំនាញសិក្សា | គ្រឹះស្ថានសិក្សា | ឆ្នាំសិក្សា |
| | | |
| | | |
| | | |

| ៣. ចំណេះដឹងភាសាបរទេស ព័ត៌មានវិទ្យា | |
|---|---|
| -កម្រិតភាសាអង់គ្លេស | ☐ មធ្យម ☐ បង្គួរ ☐ ល្អ -ភាសាផ្សេងៗ.................... ☐ មធ្យម ☐ បង្គួរ ☐ ល្អ |
| -ព័ត៌មានវិទ្យា (Microsoft Word &Excel) | ☐ មធ្យម ☐ បង្គួរ ☐ ល្អ -ផ្សេងៗ .................... ☐ មធ្យម ☐ បង្គួរ ☐ ល្អ |

**ឯកសារភ្ជាប់៖**

- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន (ថតចម្លង និងភ្ជាប់ច្បាប់ដើមសម្រាប់ផ្ទៀងផ្ទាត់)
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ថតចម្លងដែលបញ្ជាក់ការថតចម្លងត្រឹមត្រូវ)
- វិញ្ញាបនប័ត្រកុំព្យូទ័រ និងភាសាអង់គ្លេស (ថតចម្លង និងភ្ជាប់ច្បាប់ដើមសម្រាប់ផ្ទៀងផ្ទាត់)
- រូបថត ៤*៦ មួយសន្លឹក

ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសថា ព័ត៌មានដែលបានបំពេញខាងលើ និងឯកសារភ្ជាប់ទាំងអស់ ពិតជាព័ត៌មានត្រឹមត្រូវប្រាកដមែន។ ក្នុងករណី មានការក្លែងបន្លំ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ទាំងស្រុង។

ថ្ងៃ....................ខែ................ឆ្នាំ.................... ស័ក ព.ស២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១...

**ហត្ថលេខា និងឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងពាណិជ្ជកម្ម
លេខ ២២៥ ព.ណ. [illegible]

# ប្រកាស
# ស្តីពី
# ការទទួលស្គាល់អ្នកតំណាងស្របច្បាប់ ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬ ឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- ប្រកាសលេខ ២១៣ ពណ ចបព ប្រក ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- ប្រកាសលេខ១៧៨ ព.ណ នច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននាំចេញ-នាំចូល
- ប្រកាសលេខ ៣១៩៨ ព.ណ ខកល ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

# សម្រេច

## ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងដូចខាងក្រោម៖

- គ្រប់គ្រង និងពង្រឹងសមត្ថភាពអ្នកតំណាងស្របច្បាប់ របស់សហគ្រាស ក្រុមហ៊ុន
- ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ប្រកាស សេចក្តីជូនដំណឹង ពាក់ព័ន្ធដល់ការចុះបញ្ជីពាណិជ្ជកម្ម និងការផ្តល់ឯកសារទាក់ទងនឹងការនាំចេញ-នាំចូល
- គាំទ្រដល់ការផ្តល់សេវាចុះបញ្ជីពាណិជ្ជកម្មនិងសេវានាំចេញ-នាំចូល ឲ្យកាន់តែប្រសើរឡើង។

## ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវការទទួលខុសត្រូវ និងនីតិវិធី ក្នុងការទទួលស្គាល់រូបវន្តបុគ្គល និងនីតិបុគ្គលជាអ្នកតំណាងស្របច្បាប់ របស់ម្ចាស់សហគ្រាស ក្រុមហ៊ុន សម្រាប់ស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬឯកសារទាក់ទងនឹងការនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម។

## ប្រការ ៣.- វិសាលភាព៖

ប្រកាសនេះមានវិសាលភាពអនុវត្តលើការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬ ឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម ដោយអ្នកតំណាងស្របច្បាប់។

ម្ចាស់សហគ្រាស-ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលមានបំណងបង្កើតក្រុមហ៊ុន ឬ ស្នើសុំឯកសារទាក់ទងនឹងការនាំចេញ-នាំចូល អាចបំពេញបែបបទតាមការតម្រូវរបស់ក្រសួងពាណិជ្ជកម្ម ដោយខ្លួនឯងបាន។

## ប្រការ ៤.- លក្ខខណ្ឌតម្រូវចំពោះអ្នកតំណាងស្របច្បាប់

អ្នកតំណាងស្របច្បាប់របស់សហគ្រាស-ក្រុមហ៊ុន ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ឬឯកសារនាំចេញ-នាំចូល នៅក្រសួងពាណិជ្ជកម្ម គឺជា៖ រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានទទួលសិទ្ធិពីម្ចាស់សហគ្រាស-ក្រុមហ៊ុន ដើម្បីបំពេញបែបបទ និងផ្តល់ឯកសារតម្រូវនានា នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ឬនាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម។

**ក. អ្នកតំណាងស្របច្បាប់ជារូបវន្តបុគ្គល ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖**

- រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ មានអាយុចាប់ពី១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ
- បានបញ្ចប់ មធ្យមសិក្សាទុតិយភូមិ ឬមានសញ្ញាបត្រសមមូលឡើងទៅ
- មានចំណេះដឹង និងវិញ្ញាបនបត្របញ្ជាក់ការសិក្សាផ្នែកកុំព្យូទ័រ និងភាសាអង់គ្លេស
- ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាល ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម និងប្រឡងជាប់ជាស្ថាពរ
- មានលិខិតថ្កោលទោស ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច
- ត្រូវមានប្រាក់តម្កល់ចំនួន ៤ ០០០ ០០០ (បួនលាន) រៀល នៅគណនីធនាគារណាមួយសម្រាប់ធានាដល់ការបង់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។ ប្រាក់តម្កល់នេះ ត្រូវរក្សាទុករហូតដល់រូបវន្តបុគ្គលបាត់សិទ្ធិ។

**ខ. អ្នកតំណាងស្របច្បាប់ជានីតិបុគ្គល ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖**

- ត្រូវមានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម
- ត្រូវមានប័ណ្ណពន្ធប៉ាតង់ក្នុងឆ្នាំស្នើសុំចុះឈ្មោះជាអ្នកតំណាងនៅក្រសួងពាណិជ្ជកម្ម
- ត្រូវមានអ្នកតំណាងស្របច្បាប់ជារូបវន្តបុគ្គលយ៉ាងតិច ០១ (មួយ) រូប ដែលមានប័ណ្ណសម្គាល់ជាអ្នកតំណាងស្របច្បាប់ដែលនៅមានសុពលភាព
- មិនមានជាប់បណ្តឹងនៅតុលាការ។

## ប្រការ ៥.- ការបណ្តុះបណ្តាល

ក្រសួងពាណិជ្ជកម្មត្រូវរៀបចំវគ្គបណ្តុះបណ្តាលលើការងារចុះបញ្ជីពាណិជ្ជកម្មចំនួន ០២(ពីរ) វគ្គ និង ការងារនាំចេញ-នាំចូល ចំនួន ០២(ពីរ) វគ្គ ក្នុង ០១(មួយ) ឆ្នាំ។ វគ្គសិក្សាអាចរៀបចំបន្ថែមក្នុងករណីចាំបាច់។ ក្នុងករណីមានការផ្លាស់ប្តូរនីតិវិធី វិធាននានា ឬបច្ចេកវិទ្យាក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រសួងពាណិជ្ជកម្ម អាចបើកវគ្គថ្មី ឬ វគ្គបំប៉នបន្ថែម សម្រាប់អ្នកដែលបានទទួលសិទ្ធិជាអ្នកតំណាងរួចហើយ។

**១- លក្ខណៈសម្បត្តិសម្រាប់អ្នកដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល៖**

អ្នកដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាលនៅក្រសួងពាណិជ្ជកម្មត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ មានអាយុចាប់ពី១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ
- បានបញ្ចប់ មធ្យមសិក្សាទុតិយភូមិ ឬមានសញ្ញាបត្រសមមូលឡើងទៅ
- មានចំណេះដឹង និងវិញ្ញាបនបត្របញ្ជាក់ការសិក្សាផ្នែកកុំព្យូទ័រ និងភាសាអង់គ្លេស
- បំពេញពាក្យសុំចូលរួមវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម ។

**២- វគ្គបណ្តុះបណ្តាល**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម និងនាយកដ្ឋាននាំចេញ-នាំចូល ត្រូវសហការរៀបចំកម្មវិធី និងវគ្គបណ្តុះបណ្តាល ដល់អ្នកតំណាងស្របច្បាប់នូវចំណេះដឹងដូចខាងក្រោម៖

**ក. វគ្គបណ្តុះបណ្តាលលើការងារចុះបញ្ជីពាណិជ្ជកម្ម៖**

- មូលដ្ឋានគ្រឹះនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម •
- លិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងពាណិជ្ជកម្ម ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម
- បែបបទ និងនីតិវិធីដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម
- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម
- ការអនុវត្តជាក់ស្តែងក្នុងការចុះបញ្ជីពាណិជ្ជកម្ម។

**ខ. វគ្គបណ្តុះបណ្តាលលើការងារនាំចេញ-នាំចូល**

- វិធានប្រភពដើមទំនិញ
- លិខិតបទដ្ឋានគតិយុត្តិ និងនីតិវិធី ពាក់ព័ន្ធនឹងការនាំចេញ-នាំចូល
- ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម
- ការអនុវត្តជាក់ស្តែងក្នុងការស្នើសុំឯកសារនាំចេញ-នាំចូល។

**គ. កម្មវិធី និងឯកសារបណ្តុះបណ្តាល**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម និងនាយកដ្ឋាននាំចេញ-នាំចូល ត្រូវរៀបចំកម្មវិធីសិក្សា និងឯកសារសម្រាប់វគ្គបណ្តុះបណ្តាលអ្នកតំណាងស្របច្បាប់តាមការចាំបាច់។

បេក្ខជនត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាល និងការប្រឡងបញ្ចប់ដោយជោគជ័យតាមរយៈការវាយតម្លៃរបស់គណៈកម្មការវគ្គបណ្តុះបណ្តាល ដែលបង្កើតឡើងដោយក្រសួងពាណិជ្ជកម្ម។ បេក្ខជនដែលបានប្រឡងជាប់នឹងត្រូវបានផ្តល់វិញ្ញាបនបត្របញ្ជាក់ការសិក្សា ដើម្បីចុះឈ្មោះ ក្នុងបញ្ជីយកប័ណ្ណ សម្គាល់អ្នកតំណាងស្របច្បាប់។

## ប្រការ ៦.- បញ្ជីឈ្មោះ ប័ណ្ណសម្គាល់ និង ទំហំការងាររបស់អ្នកតំណាងស្របច្បាប់

**ក. បញ្ជីឈ្មោះ**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម និងនាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំបញ្ជីឈ្មោះអ្នកតំណាងស្របច្បាប់ ដែលមានចុះព័ត៌មានដូចខាងក្រោម៖

- ឈ្មោះរូបវន្តបុគ្គល ឬនីតិបុគ្គល និងអាសយដ្ឋានបច្ចុប្បន្ន
- កាលបរិច្ឆេទនៃការចុះឈ្មោះក្នុងបញ្ជីអ្នកតំណាង
- លេខប័ណ្ណសម្គាល់ កាលបរិច្ឆេទចុះបញ្ជី និងសុពលភាព។

ខ. សុពលភាពនៃប័ណ្ណសម្គាល់

រូបវន្តបុគ្គល ដែលបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៤ ខាងលើ អាចមកទទួលប័ណ្ណសម្គាល់ពីក្រសួងពាណិជ្ជកម្មដែលមានសុពលភាព ០២(ពីរ)ឆ្នាំ និងអាចបន្តសុពលភាព ០២(ពីរ) ឆ្នាំម្តង តាមការស្នើសុំរបស់អ្នកតំណាងស្របច្បាប់យ៉ាងតិច ៣០ថ្ងៃ មុនពេលអស់សុពលភាព។

គ. ទំហំការងាររបស់អ្នកតំណាងស្របច្បាប់សម្រាប់ស្នើសុំឯកសារនាំចេញ-នាំចូល

អ្នកតំណាងស្របច្បាប់ ០១(មួយ) រូប ឬ ០១(មួយ) ក្រុមហ៊ុន អាចធ្វើជាអ្នកតំណាងឲ្យសហគ្រាស-ក្រុមហ៊ុន បានត្រឹមចំនួន ០៥ (ប្រាំ) សហគ្រាស-ក្រុមហ៊ុនតែប៉ុណ្ណោះ។ ក្នុងករណីអ្នកតំណាងស្របច្បាប់មានការចាំបាច់ត្រូវធ្វើជាអ្នកតំណាងឲ្យ សហគ្រាស-ក្រុមហ៊ុន ច្រើនជាង ០៥(ប្រាំ) នោះត្រូវដាក់ពាក្យសុំការអនុញ្ញាតពី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ ៧.- ការទទួលខុសត្រូវរបស់អ្នកតំណាងស្របច្បាប់**

អ្នកតំណាងស្របច្បាប់ របស់ម្ចាស់សហគ្រាស-ក្រុមហ៊ុន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវព័ត៌មាន និងឯកសារដែលបានប្រកាស។ ក្នុងករណីរកឃើញថា ព័ត៌មាន ឬឯកសារដែលបានផ្តល់ព័ត៌មានការក្លែងបន្លំ ឬមិនពិត ឬបង្កកឯកសារមិនផ្តល់ជូនសហគ្រាស-ក្រុមហ៊ុន ដែលបានប្រគល់សិទ្ធិ ដើម្បីកេងយកប្រយោជន៍ផ្ទាល់ខ្លួន ឬបក្ខពួកខ្លួន អ្នកតំណាងស្របច្បាប់នោះនឹងត្រូវបានដកហូតសិទ្ធិជាអ្នកតំណាងស្របច្បាប់ និងទទួលទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រមទាំងប្បញ្ញត្តិច្បាប់ជាធរមានផ្សេងទៀត។

**ប្រការ ៨.- ការបាត់បង់សិទ្ធិជាអ្នកតំណាង**

អ្នកតំណាងស្របច្បាប់ត្រូវបាត់បង់សិទ្ធិក្នុងការធ្វើជាអ្នកតំណាង ក្នុងករណីណាមួយ ដូចខាងក្រោម៖

- មិនបានស្នើសុំបន្តសុពលភាពនៃប័ណ្ណសម្គាល់ តាមការកំណត់នៅក្នុងប្រការ៦
- ស្នើសុំលាលែងជាលាយលក្ខណ៍អក្សរ
- មិនបានបំពេញការបណ្តុះបណ្តាលបន្ថែមតាមការរៀបចំដោយក្រសួងពាណិជ្ជកម្ម
- មិនបានអនុវត្តត្រឹមត្រូវតាមប្រកាសជាធរមានរបស់ក្រសួងពាណិជ្ជកម្ម និងប្បញ្ញត្តិច្បាប់នានារបស់ព្រះរាជាណាចក្រកម្ពុជា
- មានលិខិតបញ្ជាក់ពីការអសមត្ថភាពផ្នែកសតិស្មារតី ដែលមិនអាចបំពេញមុខងាររបស់ខ្លួនបាន។

**ប្រការ ៩.- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងការប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១០.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

<u>ចម្លងជូន៖</u>

- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន***
- *ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *សាលារាជធានី ខេត្ត*
- *ដូចប្រការ១០*
- *សមាគមរោងចក្រកាត់ដេរនៅកម្ពុជា **"ដើម្បីជូនជ្រាប"***
- *ឯកសារ-កាលប្បវត្តិ*